**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៥៥៥...សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៥ខែសីហា ឆ្នាំ២០១៥

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងថ្នាក់ដារបើកផ្តល់ សម្រាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ជូនមន្ត្រីរាជការនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ១១៥ សហវ.ម.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកា


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
... Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

គណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## សម្រេច

**ប្រការ១:** ប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នឹងត្រូវបើកផ្តល់តាមរយៈភ្នាក់ងារបើកផ្តល់។

**ប្រការ២:** ត្រូវបានតែងតាំង ÷

- លោក **ថាន់ ម៉េងលាង** ឋានៈ មន្ត្រីការិយាល័យគណនេយ្យ ជាភ្នាក់ងារបើកផ្តល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- លោកស្រី **ឈឹម ឆដា** ឋានៈ មន្ត្រីការិយាល័យគណនេយ្យ ជាភ្នាក់ងារបើកផ្តល់ជំនួស។

**ប្រការ៣:** លោក **ថាន់ ម៉េងលាង** និងលោកស្រី **ឈឹម ឆដា** ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីទទួលមូលនិធិ សម្រាប់យកទៅបើកប្រាក់បៀវត្សរ៍ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ។

**ប្រការ៤:** បែបបទនៃការអនុវត្តបើកផ្តល់បៀវត្សរ៍និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ត្រូវបានកំណត់ដោយសេចក្តីណែនាំជាក្រោយ។

**ប្រការ៥:** ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាសនិងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

**ប្រការ៦:** សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧:** នាយកខុទ្ទកាល័យអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃនាយកដ្ឋានថវិកា ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ព្រមទាំងលោក **ថាន់ ម៉េងលាង** និង លោកស្រី **ឈឹម ឆដា** មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

ជ.សាកលវិទ្យាធិការ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

បណ្ឌិត ជេត ជាលី

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ